USAID
FROM THE AMERICAN PEOPLE

Health Systems Strengthening in Cambodia
URC

# សម្លេង USAID HSSC

គំរោងពង្រឹងប្រព័ន្ធសុខាភិបាលកម្ពុជារបស់ទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក អនុវត្តដោយអង្គការ URC

លេខ៦ ខែមីនា ឆ្នាំ២០០៧

# ពង្រឹងប្រពន្ធ័សុខាភិបាលតាមរយៈការអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រង

គំរោងពង្រឹងប្រព័ន្ធសុខាភិបាលកម្ពុជារបស់ទីភ្នាក់ងារ ដើម្បីការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក អនុវត្តដោយអង្គការយូអារស៊ី (USAID-HSSC/URC) កំពុងសហការណ៍ជាមួយក្រសួងសុខាភិបាលដើម្បីអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងដល់មន្ត្រីសុខាភិបាលនៅខេត្តក្រុងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា គឺះ ក្រុងភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង ក្រចេះ ពោធិសាត់ និងក្រុងព្រះសីហនុ។

## ការរៀបចំអភិវឌ្ឍន៍ និងការអនុវត្តនូវផែនការប្រតិបត្តិប្រចាំឆ្នាំ

ក្រសួងសុខាភិបាលបានផ្តល់មគ្គទេសក៏ដល់មន្ត្រីសុខាភិបាលថ្នាក់ខេត្ត និងស្រុកអំពីការងារអភិវឌ្ឍន៍ផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងនោះមានទាំងការចង្អុលបង្ហាញនូវកន្សោមអាទិភាព និងយុទ្ធសាស្ត្រគន្លឹះ សំរាប់ជាជំនួយដល់ការស្វែងរកធនធាន។ អ្នកសំរបសំរួលខេត្តរបស់អង្គការយូអារស៊ីនៅតាមខេត្តនិមួយៗ បានសហការណ៏និងផ្តល់ជំនួយបច្ចេកទេសសំរាប់ការរៀបចំអភិវឌ្ឍន៍នូវផែនការប្រតិបត្តិនិងការតាមដានអនុវត្តផែនការប្រចាំឆ្នាំ ដោយផ្អែកតាមមគ្គទេសក៏របស់ក្រសួងសុខាភិបាល។ ជំហ៊ានដំបូងនៃការអភិវឌ្ឍន៍ផែនការប្រតិបត្តិ គឺការវិភាគស្ថានភាពឱ្យបានស៊ីជំរៅ តាមរយៈនេះមន្ត្រីសុខាភិបាលអាចកំណត់នូវកន្សោមអាទិភាពសំខាន់ៗ ព្រមទាំងកំណត់នូវគោលដៅ និងគោលដៅចំនុចសំរាប់អនុវត្តនាពេលអនាគត។ ដើម្បីឱ្យមានកិច្ចសហការ និងការគាំទ្រផ្នែកថវិកាបានល្អប្រសើរឡើង គ្រប់ភាគីអភិវឌ្ឍន៍សុខាភិបាលទាំងអស់ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការរៀបចំអភិវឌ្ឍន៍ និង ការតាមដានលើការអនុវត្តន៏ផែនការប្រតិបត្តិប្រចាំឆ្នាំប្រចាំឆ្នាំ។



អ្នកសំរបសំរួលអង្គការយូអារស៊ីប្រចាំខេត្តបន្ទាយមានជ័យ និងមន្ត្រីស្រុកប្រតិបត្តិព្រះនេត្រព្រះកំពុងពិភាក្សា ដើម្បីកំណត់នូវកំណត់នូវគោលដៅ និងគោលដៅចំនុចសំរាប់ការអភិវឌ្ឍន៍ផែនការប្រចាំឆ្នាំរបស់ខ្លួន

**យុទ្ធសាស្ត្រចំបងៗដើម្បីអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងរួមមានះ**

១. ការរៀបចំអភិវឌ្ឍន៍ និងការអនុវត្តនូវផែនការប្រតិបត្តិប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព

២. គាំទ្រយន្តការសំរបសំរួលថ្នាក់ខេត្តតាមរយៈការប្រជុំ **ក្រុមការងារបច្ចេកទេសសុខាភិបាលខេត្ត**

៣. ពង្រឹងជំនាញដល់អ្នកអភិបាលថ្នាក់មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ

៤. ពង្រឹងសមត្ថភាពគ្រប់គ្រងដល់មន្ត្រីដឹកនាំរបស់មន្ទីរសុខាភិបាល និងស្រុកប្រតិបត្តិតាមរយៈឧបករណ៏វាយតំលៃសំរាប់មន្ទីរសុខាភិបាល និងស្រុកប្រតិបត្តិ។

៥. ការតាមដានលើការអនុវត្តន៏សកម្មភាព។